# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ១៣០ ក្រ៦ "ស"

-ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ ២៦១៤

ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១

-សំណុំរឿងស៊ើបសួរលេខ ១៩៤១

ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១

-សំណុំរឿងជំនុំជម្រះលេខ ៤០៦៧

ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងរាជធានីភ្នំពេញ

កាលបរិច្ឆេទបើកសវនាការ ៖ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង៨ ព្រឹក

កាលបរិច្ឆេទប្រកាសសាលក្រម៖ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង១០ និង ៣០នាទីព្រឹក

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ជាប្រធានក្រុមប្រឹក្សាសាលាដំបូងរាជធានីភ្នំពេញ

លោក [redacted] ជាចៅក្រមប្រឹក្សាសាលាដំបូងរាជធានីភ្នំពេញ

លោកស្រី [redacted] ជាចៅក្រមប្រឹក្សាសាលាដំបូងរាជធានីភ្នំពេញ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ២៦១៤ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១ ដែលមាន**ជនជាប់ចោទ**៖

-ឈ្មោះ[redacted]**ដា** ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ចាម មានទីលំនៅមុនឃាត់ខ្លួននៅស្នាក់នៅផ្ទះជួលគ្មានលេខ ផ្លូវជាតិលេខ៦A សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] **ម៉ៅ** (ស្លាប់) ម្តាយឈ្មោះ[redacted] **យើ** (ស្លាប់) ប្រពន្ធឈ្មោះ**ជ័យ សុមុន្នី** មានកូនចំនួន១នាក់ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារកាលពីឆ្នាំ២០១៤ រយៈពេល៦ខែពីបទលួច ជាទីតិជន ។

-តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ៤៦៧៨"អ" ជ.ឃ.ជ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ ។

មានលោកស្រី [redacted] ជាមេធាវីការពារក្តី ។

ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារគាស់ទម្លុះទម្លាយ** តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្ទះលេខV03A ផ្លូវជាតិលេខ៦A ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] **រួចណៃ** ភេទស្រី អាយុ៤៤ឆ្នាំ ជាតិខ្មែរ អាសយដ្ឋាននៅបុរីប្រេហ្គនជ្រោយចង្វារ ផ្ទះលេខV03A ផ្លូវជាតិលេខ៦A ក្រុមទី១៣ ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។

មេធាវីតំណាងដោយអាណត្តិលោក [redacted]

## <u>**អង្គហេតុនៃរឿងមានដូចតទៅ**</u>

កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង២៣ និង៣០នាទី មានករណីអំពើលួចមានស្ថានទម្ងន់ទោស ដោយសារគាត់ទំលុះទំលាយ (គាស់ទ្វារចូលលួចទ្រព្យសម្បត្តិ) ប្រព្រឹត្តនៅចំណុចផ្ទះលេខV03A ផ្លូវជាតិលេខ៦A ក្រុម ១៣ ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ បង្កឡើងដោយជនជាប់ចោទម្នាក់ឈ្មោះ[redacted] **ដា** បាន ដើរចេញពីផ្ទះជួលគ្មានលេខ ផ្លូវជាតិលេខ៦A សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ មកពួនសម្ងំក្នុងដីឡូតិ៍គ្មានលេខ ជិតបុរីប្រេហ្គនជ្រោយចង្វារ លុះដល់វេលាកើតហេតុ ជនជាប់ចោទក៏បានឡើងតាមដំបូលខាងក្រោយមកធ្វើសកម្មភាពយកដែកទាញគាស់បង្អួចផ្ទះរបស់ជនរងគ្រោះឈ្មោះ[redacted] **រួចណៃ** រួចចូលទៅក្នុងផ្ទះលួចយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះបានសម្រេចរួចគេចខ្លួនបាត់ ។ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ ជនរងគ្រោះឈ្មោះ[redacted] **រួចណៃ** បានមកដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលជ្រោយចង្វារ សំណូមពរសមត្ថកិច្ចជួយស្រាវជ្រាវស្វែងរកទ្រព្យសម្បត្តិរបស់ខ្លួនដែលជនជាប់ចោទធ្វើសកម្មភាពលួចយកទៅមានដុំមាសមួយដុំទម្ងន់កន្លះគីឡូ ,ប្រាក់រៀលចំនួន៤.000.000រៀល , ប្រាក់ដុល្លារចំនួន៥00ដុល្លារអាមេរិក ,ពេជ្រពីរឈុតតម្លៃ៣៨000ដុល្លារអាមេរិក និងទូរស័ព្ទដៃម៉ាកអាយហ្វូន១១ប្រូ ស៊ីមកាតលេខ0៨៥ ៦៦១ ២១៥ ចំនួន១គ្រឿង និងចាប់ជនល្មើសផ្តន្ទាទោសតាមច្បាប់ ។ ទើបនៅថ្ងៃទី0១ ខែកក្កដា ឆ្នាំ ២0២១ វេលាម៉ោង១៦ និង00នាទី កម្លាំងការិយាល័យបានស្រាវជ្រាវឃាត់ខ្លួនជនជាប់ចោទចំនួន១នាក់ ឈ្មោះ[redacted] **ដា** នៅចំណុចខាងលិចគល់ស្ពានជ្រោយចង្វារ ផ្លូវលេខ៤៧ កែងផ្លូវជាតិលេខ៥ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រព្រឹត្តបទល្មើសនិងចាប់យកប្រាក់ដុល្លារចំនួន២២000ដុល្លារអាមេរិក (ពីរម៉ឺនពីរពាន់ដុល្លារអាមេរិក) ,នាឡិកាដៃចំនួន១គ្រឿងម៉ាក LONGINE ខ្សែពណ៌ខ្មៅ ,ទូរស័ព្ទដៃម៉ាកអាយហ្វូនម៉ាក11 Promax ពណ៌បៃតង បញ្ជូនមកការិយាល័យនាំនាំខ្លួនជនជាប់ចោទឈ្មោះ[redacted] **ដា** ទៅចង្អុលហាងមាស កន្លែងដែលជនជាប់ចោទបានយកមាសដុំទៅលក់នៅហាងពេជ្រគន្លាលក់គ្រឿងអលង្ការគ្រប់ប្រភេទ មានទីតាំងស្ថិតនៅផ្ទះលេខ១៨-២០ ផ្លូវលេខ១២៨ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពេលទៅដល់សមត្ថកិច្ចបានជួបឈ្មោះ[redacted] **ប៊ុនហេង** ដែលជាអ្នកទទួលទិញដុំមាសពីជនជាប់ចោទ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ ដោយពុំបានសួរនាំព័ត៌មានអ្វីទាំងអស់ ដោយគ្រាន់តែយកមាសទៅពិនិត្យមើលថាសុទ្ធ រឺមិនសុទ្ធ រួចទូទាត់ប្រាក់ឲ្យជនជាប់ចោទក្នុងតម្លៃទីផ្សារ បន្ទាប់មកសមត្ថកិច្ចបាននាំខ្លួនឈ្មោះ[redacted] **ប៊ុនហេង** មកធ្វើការសាកសួរ ។

-**បានឃើញ** របាយការណ៍សំយោគលេខ១៨៣/២០២១ រ.ប.ក ចុះថ្ងៃទី0៣ ខែកក្កដា ឆ្នាំ២០២១ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាល ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ១៩៨៦ អ.យ.ឆ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ កំណត់ហេតុទទួលវត្ថុចាប់យកលេខ១១២៧ រ.វ.ត ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូង និង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ៣៧៣៣ អ.យ.ឆ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ របស់លោក[redacted] របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៥១៩១ "ឆ"ដ.ង ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់លោកស្រី [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## <u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ[redacted] ផា បានឆ្លើយថា៖កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង២៣ និង៣០នាទីយប់ ខ្លួនធ្វើសកម្មភាពគាស់បង្អួចផ្ទះលេខV08A ផ្លូវជាតិលេខ៦A ក្រុម១៣ ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ បានលួចយកទ្រព្យសម្បត្តិក្នុងផ្ទះ(ដែលម្ចាស់ស្រីម្នាក់កំពុងដេកលក់នៅក្នុងបន្ទប់) ដូចជា កាបូបយួរដៃពណ៌ខ្មៅតចំនួន១ ក្នុងកាបូបនោះមានលុយចំនួន៣.០០០.០០០(បីលានរៀល) និងលុយដុល្លារចំនួន៧០$ មាស១ដុំ នៅក្នុងទូរក្បាលដំណេក នាឡិកាដៃ១គ្រឿង និងទូរស័ព្ទដៃម៉ាក Iphone 11 promax (អាយហ្វូន១១ប្រូម៉េក) ដែលគេបានដាក់នៅលើតុ ក្រោយពីប្រមូលយកសម្ភារៈទាំងអស់ខាងលើហើយ ខ្លួនចុះត្រឡប់ទៅផ្ទះជួលដេកជាមួយប្រពន្ធវិញ តែប្រពន្ធខ្លួនមិនដឹងទេ ព្រោះខ្លួនយកទៅលាក់ទុក ។ លុះដល់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង១០ និង៣០នាទីព្រឹក ខ្លួនក៏បានយកដុំមាសនោះទៅលក់នៅហាងមាសយីហោឈ្មោះ[redacted] គន្ធា ([redacted] ប៊ុនហេង) ស្ថិតនៅផ្ទះលេខ១៨២០ ផ្លូវកម្ពុជាក្រោម(១២៨) សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពេលនោះមានកូនជាងម្នាក់យកមាសនោះទៅដុតមើលសុទ្ធហើយថ្លឹងឃើញមាសទម្ងន់១៣តម្លឹង៣ជី៥ហ៊ុន៣លី និងព្រមព្រៀងទិញក្នុងតម្លៃប្រាក់ ២៧៧៧៤ (ពីរម៉ឺនប្រាំពីរពាន់ប្រាំពីររយចិតសិបបួន)ដុល្លារអាមេរិក ហើយម្ចាស់ហាង(មនុស្សប្រុស) បានសរសេរវិក្កយបត្រ និងរាប់ប្រាក់ប្រគល់មកឲ្យខ្លួនគ្រប់ចំនួន ។ បន្ទាប់ពីលក់មាសបានប្រាក់រួចហើយ ខ្លួនបានយកប្រាក់នោះទៅលាក់ទុកនៅផ្ទះជួលរបស់ខ្លួនដោយពុំបានឲ្យក្រុមគ្រួសាររបស់ខ្លួនដឹងឡើយ ។ លុះដល់ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ខ្លួនយកលុយនោះទៅទិញឡាន LEXUS RX330 តម្លៃ២៦០០០(ពីរម៉ឺនប្រាំមួយពាន់ដុល្លារអាមេរិក) ។ រួចខ្លួនបានជិះដើរលេងជាមួយមិត្តភក្តិដោយមិនឲ្យប្រពន្ធដឹង ហើយខ្លួនបានយកទៅផ្ញើនៅការ៉ាស់ឡានរបស់គេ ព្រោះវាខូច ចំណែកឯលុយសល់ពីទិញឡានខ្លួនបានយកទៅស៊ីចាយអស់ជាមួយមិត្តភក្តិ ។ ចំពោះទូរស័ព្ទដៃម៉ាក Iphone 11 promax មួយគ្រឿងខ្លួនបានទុកប្រើ ចំណែកឯស៊ីមខ្លួនកាច់ចោល ហើយយកទៅដាក់ស៊ីមថ្មី ឯនាឡិកខ្លួនទុកប្រើដែរ ។ ក្រោយពីសមត្ថកិច្ចចាប់ឃាត់ខ្លួន បានដកហូតយកសម្ភារៈទូរស័ព្ទដៃ នាឡិកា និងដកហូតទូរសព្ទដៃម៉ាក អាយហ្វូនអ៊ិច បៃកអេក្រង់១គ្រឿង ហើយខ្លួនបានលក់ឡាន

LEXUS RX330 បានចំនួន២២០០០$ (ពីរម៉ឺនពីរពាន់ដុល្លារអាមេរិក) ប្រគល់លុយឱ្យទៅម្ចាស់ដើមវិញ (លុយលក់មាសទិញឡាន) ដោយមានរូបថតជាភស្តុតាង ។

-ក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] រួចហៃ នៅចៅក្រមស៊ើបសួរ បានឆ្លើយថា៖ កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង២២ និង៣០នាទីយប់ ខ្លួនបានចូលសម្រាកក្នុងបន្ទប់ម្នាក់ឯង ចំណែកកូន ម៉ាក់ប៉ា គេងបន្ទប់ផ្សេង នៅជាន់ទី១ ដូចគ្នា ចំណែកជាន់ផ្ទាល់ដីមានប្អូនប្រុសគេង និងឈ្នួលគេងនៅបន្ទប់ផ្ទះបាយរួចបានបិទភ្លើង ។ លុះព្រឹកឡើងម៉ោង៧ព្រឹកខ្លួនរកទូរស័ព្ទដែលខ្លួនទុកនៅលើតុជាប់ក្បាលគ្រែមើលម៉ោងស្រាប់តែរកមិនឃើញ រួចខ្លួនបានបើកភ្នែកស្រាប់តែឃើញឥវ៉ាន់រាយប៉ាយពេញក្នុងបន្ទប់ បន្ទាប់មកខ្លួនក៏បានដើរមើលសម្ភារៈនៅក្នុងកូនតុក្បែរគ្រែខ្លួនគេងដូចជា៖មាសមួយដុំ ១៣តម្លឹងស្មើរនឹងកន្លះគីឡូ តម្លៃ២៩២០៩(ពីរម៉ឺនប្រាំបួនពាន់ពីររយប្រាំបួន)ដុល្លារអាមេរិក គ្រឿងពេជ្រចំនួន២ឈុត ស្មើតម្លៃ៣៨០០០(បីម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) លុយខ្មែរចំនួន៤.០០០.០០០(បួនលាន)រៀល និងលុយដុល្លារចំនួន៥០០(ប្រាំរយ)ដុល្លារអាមេរិក ដាក់ក្នុងកាបូបពណ៌ខ្មៅ នៅលើទូរតាំង ចំណែកឯទូរស័ព្ទ និងនាឡិកាដៃខ្លួនដាក់នៅលើតុក្បែរគ្រែ បាត់ទាំងអស់ ។ បន្ទាប់ពីពិនិត្យឃើញបាត់សម្ភារៈអស់ហើយ ខ្លួនបានប្រាប់បងប្អូនម៉ែឪជួយដើរពិនិត្យមើលក្នុងផ្ទះនិងជុំវិញផ្ទះ ក៏ឃើញមានបង្អួចបន្ទប់ទឹករបើក ល្មមខ្លួនមនុស្សលូនចូលរួច រួចក៏ឃើញមានដានជើងមនុស្សឡើងតាមដំបូលផ្ទះបាយ សរសៀរចូលទៅគាស់បង្អួចបន្ទប់ទឹកតែម្ដង ។ ក្រោយពីឃើញបាត់សម្ភារៈនៅក្នុងបន្ទប់អស់ហើយខ្លួនបានរាយការណ៍ទៅសន្តិសុខយាមនៅក្នុងបុរី ហើយក៏បានដាក់ពាក្យបណ្ដឹងទៅប៉ូលីសប៉ុស្តិ៍ជ្រោយចង្វារ រៀបរាប់សម្ភារៈដែលបាត់ដូចខ្លួនរៀបរាប់ខាងលើ ។ លុះដល់ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង១រសៀល មានសមត្ថកិច្ចជ្រោយចង្វារបានទូរស័ព្ទប្រាប់ខ្លួនថា ចាប់ចោរដែលគាស់ផ្ទះលួចសម្ភារៈបាន ។ ទើបដល់ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោងប្រហែល៩ព្រឹក ខ្លួនបានទៅប៉ុស្តិ៍ជាមួយប្អូនប្រុសម្នាក់ ពេលទៅដល់បានឃើញមុខចោរច្បាស់ និងសមត្ថកិច្ចបានបង្ហាញសម្ភារៈរបស់ខ្លួនដូចជានាឡិកាដៃម៉ាក ឡុកស៊ីន ពណ៌សខ្សែខ្មៅ ទូរស័ព្ទដៃ១គ្រឿងម៉ាក 11 promax ពណ៌បៃតង ខ្លួនបានឆ្លើយប្រាប់សមត្ថកិច្ចថាជារបស់ខ្លួនពិតប្រាកដ ។ បន្ទាប់មកសមត្ថកិច្ចសួរជនជាប់ចោទរកមាសចំនួន១៣តម្លឹង វាបានឆ្លើយថាវាលក់បាត់ហើយ នៅហាងយីហោ [redacted] គន្ធាហៅ[redacted] ប៊ុនហេង នៅផ្ទះលេខ១៨-២០ ផ្លូវកម្ពុជាក្រោម(១២៨) សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ បានតម្លៃ២៧៧៧៤ (ពីរម៉ឺនប្រាំពីរពាន់ប្រាំពីររយចិតសិបបួន)ដុល្លារអាមេរិក ចំណែកគ្រឿងពេជ្រចំនួន២ឈុន វាថាមិនដឹងទេ ។ បន្ទាប់ពីសមត្ថកិច្ចសួរចម្លើយចប់ សមត្ថកិច្ចបានប្រគល់សម្ភារៈមកឱ្យខ្លួនវិញដូចជា នាឡិកាដៃ១គ្រឿង ទូរស័ព្ទដៃ១គ្រឿង និងលុយសុទ្ធចំនួន២២០០០ (ពីរម៉ឺនពីរពាន់)ដុល្លារអាមេរិក មកឱ្យខ្លួនក្រៅពីនោះខ្លួនមិនបានទទួលទេ ។ ខ្លួនសូមសំណូមពរសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតឹងរឹងបំផុត ទាមទារសម្ភារៈដែលបានបាត់បង់ស្មើនឹងទឹកប្រាក់ចំនួន៤៦៧០៩ (បួនម៉ឺនប្រាំមួយពាន់ប្រាំពីររយប្រាំបួន)ដុល្លារអាមេរិក និងទាមទារការខាតបង់ពេលវេលា ជម្ងឺចិត្តសរុបចំនួន២០០០០ (ពីរម៉ឺន)ដុល្លារអាមេរិក ។

-ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីឈ្មោះ[redacted]សុគន្ធា បានឆ្លើយនៅចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ វេលាប្រហែលចន្លោះម៉ោង១០ និង០០នាទី និងម៉ោង១១ និង០០នាទី ពេលនោះមានបុរសប្ដី ប្រពន្ធ និងកូនតូចម្នាក់បានមកកន្លែងហាងលក់មាសឈ្មោះ[redacted] គន្ធា បានលក់មាសទម្ងន់១៣,៣៥៣(ដប់បីតម្លឹងបីជីប្រាំហ៊ុនបីលី) ពេលនោះខ្លួនបានឱ្យបុគ្គលិកម្នាក់ដុតពិនិត្យលើមាសនោះរួច (ថាមាសសុទ្ធ ឬមិនសុទ្ធ) រួចបុគ្គលិកខ្លួនប្រាប់ថាសុទ្ធ ទើបទទួលទិញ ក្នុងតម្លៃមួយជី ចំនួន២០៨$ (ពីររយប្រាំបី)ដុល្លារអាមេរិក ដូចមាននៅក្នុងវិក័យបត្រលក់គ្រឿងអលង្ការគ្រប់ប្រភេទឈ្មោះ[redacted] គន្ធា ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ ។ អ្នកលក់បានជួបជាមួយបុគ្គលិកខ្លួនឈ្មោះ[redacted] **ប៊ុនហេង** ជាអ្នកទទួលទិញមាសនោះក្នុងតម្លៃហាងឆេងទីផ្សារជាក់ស្ដែង ក្នុងថ្ងៃទិញលក់ (ឯកសារភស្តុតាងដាក់បញ្ចូល) ហើយក្នុងពេលនោះខ្លួនជាម្ចាស់ហាងក៏បាននៅទីនោះដែរ ហើយបានប្រគល់ប្រាក់ដែលទិញមាសនោះតាមរយៈឈ្មោះ[redacted] **ប៊ុនហេង** ទៅឱ្យអ្នកលក់មាសនោះ ។ ក្នុងពេលបុរសប្ដីប្រពន្ធ និងកូនតូចម្នាក់បានយកមាសដុំទម្ងន់ខាងលើមកលក់ គឺខ្លួនពុំបានសួរប្រភពថាគាត់បានទិញមាសនេះពីកន្លែងណាទេ ហើយក៏ពុំបានសួររកវិក័យបត្រលក់មាសនោះដែរ មូលហេតុដែលខ្លួនមិនបានសួរលើចំណុចនេះ ដោយសារតែកន្លងមកខ្លួនធ្លាប់សួរសំណួរនេះទៅអតិថិជនជាច្រើនមកហើយ ប៉ុន្តែភាគច្រើនអតិថិជនគាត់អន់ចិត្ត ថាអ្នកទិញមានការរើសអើង ទើបខ្លួនបានប្រាប់ទៅបុគ្គលិកទាំងអស់ឱ្យឈប់សួរសំណួចនេះទៅ ។ លុះនៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង១២ និង០០នាទី ស្ថិតនៅកន្លែងហាងមាសរបស់ខ្លួន ស្រាប់តែមានសមត្ថកិច្ចនគរបាលបានចុះមកសួរនាំរកអ្នកចុះហត្ថលេខាលើវិក័យបត្រទិញមាស ។ បន្ទាប់មកមេធាវីរបស់ខ្លួនក៏បាននាំឈ្មោះ[redacted] **ប៊ុនហេង** ទៅកន្លែងសមត្ថកិច្ចដើម្បីបំភ្លឺព័ត៌មានអំពីការទិញ លក់មាសជូនសមត្ថកិច្ចរួចហើយសមត្ថកិច្ចក៏ឱ្យបុគ្គលិករបស់ខ្លួនត្រលប់មកផ្ទះវិញធម្មតា ។ កន្លងមកហាងលក់មាសខ្លួនតែងតែត្រួតពិនិត្យលើការទិញមាសរបស់អតិថិជនទាំងអស់ ហើយទិញទៅតាមហាងឆេងទីផ្សារឡើងចុះរាល់ថ្ងៃ មិនដែលទិញក្រោមហាងឆេងទេ ។ ចំពោះការទិញមាសនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ នោះខ្លួន និងបុគ្គលិកមិនបានដឹងថា អ្នកលក់មាសនោះជាចោរទេ បើដឹងខ្លួនមិនទទួលទិញ និងរាយការណ៍ជូនសមត្ថកិច្ចចាត់ការតាមនីតិវិធីច្បាប់ហើយ ។ ហាងមាសខ្លួនពុំដែលមានរឿងទិញលក់របស់ចោរទេ កន្លងមកគឺខ្លួនរកស៊ីដោយភាពត្រឹមត្រូវតាមផ្លូវច្បាប់ប៉ុណ្ណោះ ។ ខ្លួនសូមបញ្ជាក់ថា ចំពោះឈ្មោះ[redacted] **ប៊ុនហេង** ជាបុគ្គលិករបស់ខ្លួនយូរមកហើយ គាត់ជាមនុស្សស្លូតបូត ស្មោះត្រង់ ហើយគាត់ចុះហត្ថលេខាលើវិក័យបត្រទិញលក់នោះ តាមតារាងហាងឆេងទីផ្សារទាំងអស់ ។

## សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារឲ្យដើមបណ្ដឹងរដ្ឋប្បវេណី

លោក [redacted] ជាមេធាវីការពារក្ដីឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted] **វួចណៃ** បានធ្វើសេចក្ដីសន្និដ្ឋានថា៖ ជនជាប់ចោទមុនធ្វើសកម្មភាពបានលួចឃ្លាំមើលដើមបណ្ដឹងរដ្ឋប្បវេណី និងបានរៀបចំគំរោងទុកជាមុន ហើយគាត់មានជំនាញក្នុងអំពើនេះ រីឯចម្លើយដោះសាររបស់ជនជាប់ចោទមិនអាចយកជាការបានទេ ។ នៅក្នុងរឿងនេះក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងទាមទារប្រាក់ថ្លៃបាត់បង់សម្ភារៈចំនួន៤៦៧០៤$(បួនម៉ឺនប្រាំមួយពាន់ប្រាំពីររយប្រាំបួន)ដុល្លារអាមេរិក និងទាមទារជម្ងឺចិត្តចំនួន២០០០០$ (ពីរម៉ឺនដុល្លារអាមេរិក) ។

## សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា ក្រោយពីបានស្ដាប់ការដេញដោលនាពេលសវនាការឃើញថាជនជាប់ចោទបានឆ្លើយសារភាពហើយថាខ្លួនពិតជាបានចូលលួចទ្រព្យសម្បត្តិមែន តំណាងអយ្យការតម្កល់ការចោទប្រកាន់ទុកជាបានការដដែល និង ប្ដឹងសុំឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ ។

## សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យជនជាប់ចោទ

លោកស្រី [redacted] ជាមេធាវីការពារក្ដីឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា៖ តាមចម្លើយរបស់កូនក្ដីខ្លួនឃើញថា កូនក្ដីខ្លួនមិនចូលធ្វើសកម្មភាពគាស់ទម្លុះទម្លាយយកសម្ភារៈគេទេ ព្រោះសម្ភារៈដែលកូនក្ដីខ្លួនលួចនៅក្នុងថតតុដោយមិនបានចាក់សោរតែប៉ុណ្ណោះ ។ ហេតុដូច្នេះស្នើសុំឱ្យតុលាការពិចារណាប្ដូរបទចោទពីបទលួចមានស្ថានទម្ងន់ទោស តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ទៅបទ លួច តាមមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌវិញ និងសុំឱ្យតុលាការពិចារណាផ្ដល់នូវស្ថានសម្រាលទោស និងបន្ធូបន្ថយចំពោះការទាមទារសំណង ។

## សម្ដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] ងា បាននិយាយសម្ដីចុងក្រោយបង្អស់ថា: សុំឱ្យបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

១-យោងតាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ និង ឆ្លងតាមការសាកសួរដេញដោលនាពេលសវនាការកំណត់បានថា កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ មានអំពើ **លួចមានស្ថានទម្ងន់ទោសដោយសារគាស់ទម្លុះទម្លាយ** តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្ទះលេខV03A ផ្លូវជាតិលេខ៦A ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ បង្កឡើងដោយឈ្មោះ [redacted] ងា ពិតប្រាកដមែន ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ងា បានឆ្លើយសារភាពថា: នៅថ្ងៃកើតហេតុខ្លួនពិតជាបានចូលទៅលួចទ្រព្យសម្បត្តិរបស់គេពិតមែន តែមិនបានគាស់ទម្លុះទម្លាយទេ ព្រោះអីវ៉ាន់នៅក្នុងថតតុ ហើយថតតុអត់បានចាក់សោរទេ ។ អីវ៉ាន់ដែលខ្លួនលួចបានរួមមាន៖ កាបូបយួរដៃពណ៌ត្នោតចំនួន១ ក្នុងកាបូបនោះមានលុយចំនួន៣.០០០.០០០



Scanned with CamScanner

(បីលានរៀល) និងលុយដុល្លារចំនួន៧០$ មាស១ដុំ នៅក្នុងទូរក្បាលដំណេក នាឡិកាដៃ១គ្រឿង និងទូរស័ព្ទដៃម៉ាក Iphone 11 promax (អាយហ្វូន១១ប្រូមេក) ក្រោយពីលួចបានហើយខ្លួនក៏ត្រលប់ទៅដេកនៅផ្ទះវិញ លុះដល់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង១០ និង៣០នាទីព្រឹក ខ្លួនក៏បានយកដុំមាសនោះទៅលក់នៅហាងមាសយីហោឈ្មោះ [redacted] គន្ធា (សាំង ប៊ុនហេង) ។

៣-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រួចណៃ បានឆ្លើយថា៖ កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០២១ វេលាម៉ោង២២ និង៣០នាទីយប់ ខ្លួនបានចូលសម្រាកក្នុងបន្ទប់ម្នាក់ឯង ចំណែកកូន ម៉ាក់ប៉ា គេងបន្ទប់ផ្សេង នៅជាន់ទី១ ដូចគ្នា ចំណែកជាន់ផ្ទាល់ដីមានប្អូនប្រុសគេង និងឈ្នួលគេងនៅបន្ទប់ផ្ទះបាយរួចបានបិទភ្លើង ។ លុះព្រឹកឡើងម៉ោង៧ព្រឹកខ្លួនរកទូរស័ព្ទដែលខ្លួនទុកនៅលើតុជាប់ក្បាលគ្រែមើលម៉ោង ស្រាប់តែរកមិនឃើញ រួចខ្លួនបានបើកភ្នែក ស្រាប់តែឃើញឥវ៉ាន់រាយប៉ាយពេញក្នុងបន្ទប់ បន្ទាប់មកខ្លួនក៏បានដើរមើលសម្ភារៈនៅក្នុងកូនតុក្បែរគ្រែខ្លួនគេងដូចជា៖ មាសមួយដុំ ១៣តម្លឹងស្មើរនឹងកន្លះគីឡូ តម្លៃ២៩២០៩(ពីរម៉ឺនប្រាំបួនពាន់ពីររយប្រាំបួន)ដុល្លារអាមេរិក គ្រឿងពេជ្រចំនួន ២ឈុត ស្មើតម្លៃ៣៨០០០(បីម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) លុយខ្មែរចំនួន៤.០០០.០០០(បួនលាន)រៀល និងលុយដុល្លារចំនួន៥០០(ប្រាំរយ)ដុល្លារអាមេរិក ដាក់ក្នុងកាបូបពណ៌ខ្មៅ នៅលើទូរតាំង ចំណែកឯទូរស័ព្ទ និងនាឡិកាដៃខ្លួនដាក់នៅលើតុក្បែរគ្រែ បាត់ទាំងអស់ ។ បន្ទាប់ពីពិនិត្យឃើញបាត់សម្ភារៈអស់ហើយ ខ្លួនបានប្រាប់បងប្អូនម៉ែឪជួយដើរពិនិត្យមើលក្នុងផ្ទះនិងជុំវិញផ្ទះ ក៏ឃើញមានបង្អួចបន្ទប់ទឹករបើក ល្មមខ្លួនមនុស្សលូនចូលរួច រួចក៏ឃើញមានដានជើងមនុស្សឡើងតាមដំបូលផ្ទះបាយ សរសៀរចូលទៅគាស់បង្អួចបន្ទប់ទឹកតែម្តង ។ ក្រោយពីឃើញបាត់សម្ភារៈនៅក្នុងបន្ទប់អស់ហើយខ្លួនបានរាយការណ៍ទៅសន្តិសុខឃុំនៅក្នុងបុរី ហើយក៏បានដាក់ពាក្យ បណ្តឹងទៅប៉ូលីសប៉ុស្តិ៍ជ្រោយចង្វារ រៀបរាប់សម្ភារៈដែលបាត់ដូចខ្លួនរៀបរាប់ខាងលើ ។ លុះដល់ថ្ងៃទី០២ ខែកក្កដា ឆ្នាំ ២០២១ វេលាម៉ោង១រសៀល មានសមត្ថកិច្ចជ្រោយចង្វារបានទូរស័ព្ទប្រាប់ខ្លួនថា ចាប់ចោរដែលគាស់ផ្ទះលួចសម្ភារៈបាន ។ ទើបដល់ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ២០២១ វេលាម៉ោងប្រហែល៩ព្រឹក ខ្លួនបានទៅប៉ុស្តិ៍ជាមួយប្អូនប្រុសម្នាក់ ពេលទៅដល់បានឃើញមុខចោរច្បាស់ និងសមត្ថកិច្ចបានបង្ហាញសម្ភារៈរបស់ខ្លួនដូចជានាឡិកាដៃម៉ាក ឡុកស៊ីន ពណ៌សខ្សែខ្មៅ ទូរស័ព្ទដៃ១គ្រឿងម៉ាក 11 promax ពណ៌បៃតង ខ្លួនបានឆ្លើយប្រាប់សមត្ថកិច្ចថាជារបស់ខ្លួនពិតប្រាកដ ។ បន្ទាប់មកសមត្ថកិច្ចសួរជនជាប់ចោទរកមាសចំនួន១៣តម្លឹង វាបានឆ្លើយថាវាលក់បាត់ហើយ នៅហាងយីហោ [redacted] គន្ធា ហៅ [redacted] ប៊ុនហេង នៅផ្ទះលេខ១៨-២០ ផ្លូវកម្ពុជាក្រោម(១២៨) សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ បានតម្លៃ២៧៧៧៤ (ពីរម៉ឺនប្រាំពីរពាន់ប្រាំពីររយចិតសិបបួន)ដុល្លារអាមេរិក ចំណែកគ្រឿងពេជ្រចំនួន២ឈុន វាថាមិនដឹងទេ ។ បន្ទាប់ពីសមត្ថកិច្ចសួរចម្លើយចប់ សមត្ថកិច្ចបានប្រគល់សម្ភារៈមកឱ្យខ្លួនវិញដូចជា នាឡិកាដៃ១គ្រឿង ទូរស័ព្ទដៃ១គ្រឿង និងលុយសុទ្ធចំនួន២២០០០ (ពីរម៉ឺនពីរពាន់)ដុល្លារអាមេរិក មកឱ្យខ្លួនក្រៅពីនោះខ្លួនមិនបានទទួលទេ ។ ខ្លួនសូមសំណូមពរសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតឹងរឹងបំផុត ទាមទារសម្ភារៈដែលបានបាត់បង់ស្មើនឹងទឹកប្រាក់ចំនួន៤៦៧០៩ (បួនម៉ឺនប្រាំមួយពាន់ប្រាំពីររយប្រាំបួន)ដុល្លារអាមេរិក និងទាមទារការខាតបង់ពេលវេលា ជម្ងឺចិត្តសរុបចំនួន២០០០០ (ពីរម៉ឺន)ដុល្លារអាមេរិក ។

៤-តាមចម្លើយសារភាពរបស់ជនជាប់ចោទ ,ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងមានភាពស៊ីសង្វាក់គ្នា បញ្ជាក់បានថា កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង២៣ និង៣០នាទី ជនជាប់ចោទឈ្មោះ[redacted] ដា ពិតជាបានធ្វើសកម្មភាពយកដែទាញគាស់បង្អួចផ្ទះរបស់ដើមបណ្តឹងរដ្ឋប្បវេណីរួចចូលក្នុងផ្ទះលួចយកទ្រព្យសម្បត្តិ ដុំមាសមួយដុំទម្ងន់កន្លះគីឡូ ,ប្រាក់រៀលចំនួន៤.០០០.០០០រៀល ,ប្រាក់ដុល្លារចំនួន៥០០$ ,ពេជ្រពីរឈុតតម្លៃ៣៨០០០$ និងទូរស័ព្ទដៃម៉ាកអាយហ្វូន១១ប្រូ ស៊ីមកាតលេខ០៨៥ ៦៦ ១២ ១៥ ចំនួន១គ្រឿង បានសម្រេចពិតប្រាកដមែន ។

៥-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ[redacted] ដា បានដកហូតទ្រព្យ សម្បត្តិអ្នកដទៃដោយចេតនា ដែលធ្វើឱ្យប៉ះពាល់របៀបរៀបរយសង្គម សណ្តាប់ធ្នាប់សាធារណៈ គឺមានធាតុផ្សំជាបទល្មើស **លួចមានស្ថានទម្ងន់ទោស** តាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៦-ជនជាប់ចោទឈ្មោះ[redacted] ដា ជានីតិជនដែលមានសមត្ថភាព និង ស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើផ្ទាល់ខ្លួននៅពេលប្រព្រឹត្តបទល្មើស។

៧-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលហេតុ និង មូលដ្ឋានគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទឈ្មោះ[redacted] ដា ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារគាស់ទម្លុះទម្លាយ** តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្ទះលេខV03A ផ្លូវជាតិលេខ៦A ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ ។

៨-វត្ថុចាប់យកតាមកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១១២៧ វ.វ.ត ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ រួមមាន៖ ទូរស័ព្ទដៃ១គ្រឿងម៉ាក Iphone ពណ៌ទឹកមាស បែកអេក្រង់ (មិនដំណើរការ) គប្បីរឹបអូសបំផ្លាញចោល ។

៩-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] វួចណៃ ប្តឹងទាមទារសំណងការខូចខាតជាប្រាក់ចំនួន៤៦.៧០៩ (បួនម៉ឺនប្រាំមួយពាន់ប្រាំពីររយប្រាំបួន)ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តចំនួន២០០០០ (ពីរម៉ឺន)ដុល្លារអាមេរិក ពីជនជាប់ចោទឈ្មោះ[redacted] ដា តុលាការអាចពិចារណាតាមភាពជាក់ស្តែង ។

១០-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted] ដា ភេទប្រុស អាយុ៣០ឆ្នាំ ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារគាស់ទម្លុះទម្លាយ** តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្ទះលេខV03A ផ្លូវជាតិលេខ៦A ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ ។

## <u>ហេតុដូច្នេះសម្រេច</u>

១-ផ្តន្ទាទោសលើឈ្មោះ[redacted] ដា ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន **៧(ប្រាំពីរ)ឆ្នាំ** ។

ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារគាស់ទម្លុះទម្លាយ** តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្ទះលេខV03A ផ្លូវជាតិលេខ៦A ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ ។



Scanned with CamScanner

២-ឱ្យឈ្មោះ [redacted] ងា សងសំណងការខូចខាតជាប្រាក់ចំនួន៤៦.៧០៤ (បួនម៉ឺនប្រាំមួយពាន់ប្រាំពីរយប្រាំបួន) ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តចំនួន២០.០០០.០០០ (ម្ភៃលាន)រៀល ឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] វួចណៃ ការទាមទារលើសពីនេះច្រានចោល ។

៣-វត្ថុចាប់យកតាមកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១១២៧ វ.វ.ត ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញមាន៖ទូរស័ព្ទដៃ១គ្រឿងម៉ាកIphone ពណ៌ទឹកមាស បែកអេក្រង់(មិនដំណើរការ) រឹបអូសបំផ្លាញចោល

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២ ។

គូភាគីមានសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

ហត្ថលេខា និង[redacted]

......................................................................................................

**(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)**

ថ្ងៃព្រហស្បតិ៍ ២កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ,ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

[redacted]